# ពិធីពូនភ្នំខ្សាច់

នៅពេលចូលឆ្នាំថ្មី ចូលមកដល់ថ្ងៃទី ២ គឺជាវារៈវ័នបត ថ្ងៃទី ២ នេះជាថ្ងៃមួយ ដែលពុទ្ធសាសនិកខ្មែរយើងនិយមធ្វើពិធីមួយហៅថាពិធីពូនភ្នំខ្សាច់ ។ ពិធីនេះបានដក់ជាប់នៅក្នុងចិត្តរបស់ពុទ្ធសាសនិកជាយូរមកហើយ ហេតុដូចនេះហើយបានជាក្នុងពិធីបុណ្យចូលឆ្នាំថ្មី ពុទ្ធសាសនិកខ្មែរទាំងចាស់ ទាំងក្មេង ក្រមុំ កំលោះ ជញ្ជូនដីខ្សាច់យកមកចាក់គរធ្វើភ្នំ ។ ការពូនភ្នំ ឬ សាងភ្នំខ្សាច់នេះបើតាមការនិយម នឹងតាមដែលធ្លាប់ឃើញធ្លាប់ធ្វើមក គឺគេត្រូវកន្លែងណាមួយដែលស្រឡះហើយគេធ្វើរាជវ័តព័ទ្ធឱ្យធំល្មមនៅគ្រប់ទិសមានទ្វារចេញចូល៤រួចគេពូនភ្នំឬសាងភ្នំនៅក្នុងរាជវ័តិនោះ ឯភ្នំដែលពូននោះគឺត្រូវពូនភ្នំ១ ឱ្យធំនៅចំកណ្ដាល ហើយភ្នំតូចៗជាច្រើនទៀតនៅព័ទ្ធជុំវិញ ។ ភ្នំដែលបានសាង ឬពូនរួចហើយនោះ ហៅថា **វាលុកចេតិយ៍** តាម ទម្លាប់របស់បុរាណាចារ្យ គឺយកទៀន ធូប ផ្កាភ្ញី កូនទង់តូចៗទៅដោត នឹងដុតពីលើ ។

ការដែលកើតមានទំនៀមសាងវាលុកចេតិយ នេះឡើងដោយមានគតិនិយមថា សាងជាតំណាងព្រះ **ចុឡាមណិចេតិយ** ដែលពួកទេព្ដាសាងបញ្ចុះ **ព្រះកេសធាតុ, ព្រះទាឋាធាតុ (ព្រះចង្កូមកែវ)** នៅឋានត្រៃត្រិង្សសួគ៌ ដោយសម្គាល់ថាបានផលានសង្សវិសេសវិសាលផង ហើយនឹងបានជាកិច្ចរំដោះនូវគ្រោះចង្រៃក្នុងឆ្នាំចាស់ឱ្យជ្រះស្រឡះចេញផង ហើយតទៅឆ្នាំថ្មី សូមឱ្យគេបានទទួល នូវសុខសួស្ដីសិរីមង្គលវិបុលសុខ អាយុយឺនយូររកស៊ីមានបាន នឹងសូមឱ្យផុតចាកពីអន្តរាយគ្រប់យ៉ាង ឆ្នាំថ្មីជារៀងរហូតទៅ ។

ពិធីពូនភ្នំខ្សាច់នេះ **មហាសំការសូត្រ** បានបញ្ជាក់ថា : ពេលសង្ក្រាន្តឆ្នាំថ្មីចូមកដល់ ព្រះបាទបសេនទិកោសល បានចូលទៅសួរព្រះពុទ្ធថា នៅមុនពេលដែលព្រះអង្គទ្រង់បរិនិព្វានទៅ បើដល់រដូវសង្ក្រាន្តចូលឆ្នាំថ្មីម្ដងៗ តើខ្ញុំព្រះអង្គគួរបំពោញបុញ្ញកម្មអ្វីខ្លះ ? ព្រះពុទ្ធទ្រង់ត្រាស់ថា " គួរសាង **វាលុកចេតិយ** នៅឆ្នេរស្ទឹង ទន្លេ ហើយនាំយកគ្រឿងសក្ការៈមានៈ ទៀន ធូប គ្រឿងក្រអូប ផ្កា ភ្ញីជាដើមមកបូជាចុះ" ។ ព្រះអង្គបានត្រាស់បញ្ជាក់ពីអានិសង្សនៃការសាង **វលុកចេតិយ** ជា ព្រះគាថាដូច្នេះថា :

**ពាលុកចេតិយំ កត្វា យេ នរា អថ នារិយោ**

**អន្នំ បានំ វត្ថំ បុប្ផំ គន្ធវិលេបនាទីន**
**អាហរិត្វា ចេតិយំ បូជំ កត្វា សទ្ធាយ ច**
**អនិសំសំ មហប្ផលំ ទ្វេ កុលេ ឧប្បជ្ជតិ**
**ខត្តិយេ បាបិ ព្រាហ្មណេ ហីនេ កុលេ**
**ន ជាយន្តិ ពាលុកស្ស ឥទំ ផលំ ៕**

នរៈនារីណាដែលបានសាង **វាលុកចេតិយំ** ហើយយកបាយ ទឹក, សំពត់, ផ្កា, គ្រឿងក្រអូប, គ្រឿងលាបជាដើម ទៅបូជាព្រះចេតិយនោះ ដោយសទ្ធាជ្រះថ្លា នរៈ នារីនោះ រមែងបានផលានិសង្សច្រើន រមែងទៅកើតក្នុងត្រកូលពីរគឺ **ខត្តិយត្រកូល** និង **ព្រាហ្មណត្រកូល** រមែងមិនកើតក្នុងត្រកូលថោកទាបឡើយ នេះជាផលនៃការសាង **វាលុកចេតិយ** ។ មាននិទាននៅក្នុងគម្ពីរអានិសង្ស **វាលុកចេតិយ** ជាសាស្រ្តាស្លឹករឹតជាភាសារខ្មែរ មានតែមួយខ្សែ ហើយមានបីនិទាននិយាយថា :

និទានទី ១ : ដំណាលពី **បារិកពោធិសត្វ និង ពួកពាណិជ** ដែលបានពូនភ្នំខ្សាច់ ឧទ្ទិសជាតំណាង **ចូឡាមណីចេតិយ** ដែលតំកល់ព្រះចង្កូមកែវរបស់ព្រះពុទ្ធពីបុរាណប្រតិស្ឋនៅឯស្ថានត្រៃត្រិង្សទេវលោក ។ លុះអនាគតជាតិទៅ បានទៅកើតក្នុងសុគតិភពកើតជាស្តេចចក្រពត្តិជាច្រើនជាតិ ហើយទីបំផុតបានត្រាស់ជាព្រះពុទ្ធព្រះនាម **សមណគោតម** ក្នុងភទ្ទកប្បយើងនេះ ។

និទានទី ២ : ដំណាលពីនាយនេសាទម្នាក់ (ឈ្មោះមិនប្រាកដ) ដែលជាអ្នកសម្លាប់សត្វជាអាហារតាំងពីតូចមក ។ ថ្ងៃមួយអ្នកនេសាទនេះ បានប្រគេនបាយមួយពំនូត ដល់ភិក្ខុមួយរូប ។ ពេលដែលគាត់ស្លាប់ យមរាជបានយកគាត់ទៅវាយសួរចម្លើយ ហើយចាប់បោះទៅក្នុងរណ្តៅភ្លើងនរក តែមិនឆេះ បែរជាខ្ទាតចេញមកវិញ នាយយមបាលវាយសួរម្តងទៀត ។ ទទួលពេលនោះ នាយនេសាទក្រឡេកមើលទៅឃើញអណ្តាតភ្លើងនរក មានសម្បុរដូចចីវរលោក ក៏នឹកដល់ទានរបស់ខ្លួន ហើយជំរាបយមបាលតាមដំណើររឿងធ្វើទាន ។ ពួកយមបាលក៏អនុញ្ញាតឱ្យបុរសនោះ ទៅកើត

ក្នុងទេវលោកចំនួន ៧ ថ្ងៃហើយសឹមត្រឡប់មកឋាននរកវិញ ។ ទេវបុត្រនោះឈ្មោះ " **អន្លំលោ-កខ្សិនី** " មានប្រពន្ធសំណព្វចិត្តឈ្មោះនាង " **សុវណ្ណឱរ៉េ** " គាត់បាននិយាយនូវរឿងរាវរបស់គាត់ ដែលគាត់ធ្លាប់កើតក្នុងនរកនោះ ដល់ភរិយាដោយសព្វគ្រប់ ។ នាង **សុវណ្ណឱរ៉េ** ក៏ឱ្យស្វាមីរបស់ខ្លួនសាងវាលុកចេតិយហើយឱ្យឆ្លងជាស្រេចក្នុងថ្ងៃទី៧ ។ លុះដល់ថ្ងៃទី៨ យមរាជក៏មកតាមហៅ **អន្លំលោកខ្សិនីទេវបុត្រ** ទៅឋាននរកវិញ។ នាងជាប្រពន្ធក៏ចេញមក និយាយថាយើងមិនបើកទ្វារឱ្យស្វាមីរបស់យើងទៅទេ ព្រោះស្វាមីយើងបានសាងវាលុកចេតិយ នឹងធ្វើពិធីឆ្លងរួច ហើយបើនៅតែត្រូវការយកប្តីរបស់ខ្ញុំទៅធ្វើទោសនោះចូលរអ្នករាប់គ្រាប់ខ្សាច់នេះឱ្យអស់សិន ។ យមរាជក៏ចាប់ផ្តើមរាប់គ្រាប់ខ្សាច់ពេញមួយព្រឹក ដល់ថ្ងៃត្រង់នៅតែមិនអស់សោះ ។ យមរាជ ក៏ ទាល់តម្រិះហើយត្រឡប់ទៅឋាននរកវិញ ។

✿ និទានទី ៣ : ដំណាលពី **ចៅកម្ទិលខ្សាច់** ថា : មានបុរសម្នាក់ចេះតែពូនខ្សាច់នៅទីផ្នកខ្សាច់មុខផ្ទះ ហើយដេកននៀលរាល់ៗថ្ងៃប្រឡាក់ប្រឡូសទៅដោយដីខ្សច់មើលមិនយល់ គេក៏នាំគ្នាហៅថា **ចៅកម្ទិលខ្សាច់**រហូតមក ។ថ្ងៃមួយ**ព្រះឥន្ទ** ទតឃើញយ៉ាងនេះក៏ឱ្យនាង ទេពធីតាម្នាក់ចុះមកធ្វើជាប្រពន្ធ ក្រោយមកព្រះរាជាក៏ទ្រង់ចូលទីវង្គត ហើយគ្មានអ្នកណាស្នងរាជ្យពួកមន្ត្រីក៏ធ្វើបុស្បរថផ្សងរកនូវអ្នកមានបុណ្យបារមី បុស្បរថក៏ទៅត្រូវ លើ **ចៅកម្ទិលខ្សាច់** គេក៏នាំគ្នាអញ្ជើញ **ចៅកញ្ជិលខ្សាច់** នោះទៅឱ្យសោយរាជ្យជា សុខតទៅ ។

ដោយមាននិទានបែបនេះហើយ បានជាខ្មែរយើងមានជំនឿជាប់តរៀងរហូតមកដល់បច្ចុប្បន្ននេះ ។ ប៉ុន្តែភ្នំខ្សាច់នេះ មិនមែនធ្វើតែឱកាសចូលឆ្នាំទេប៉ុណ្ណោះទេ សូម្បីនៅក្នុងពិធីបុណ្យផ្សេងៗ ក៏គេនិយមធ្វើដែរ ព្រោះគេជឿជាក់ថាការរំដោះកម្មពៀរវេរាទាំងពួង ដែលបានធ្វើអាក្រក់កន្លងមក ។